**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទាំងអស់មេត្តាជ្រាបថា **ឧបាសក ទឿង ជិន** ត្រូវជាឪពុកក្មេក **ឯកឧត្តម រោង ឈង** ទីប្រឹក្សាក្រសួង បានទទួលមរណភាពនៅថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ០០:៥០នាទីព្រឹក ក្នុងជន្មាយុ៨៦ឆ្នាំ ដោយជរាពាធ។ ពិធីបូជាសពនឹងប្រព្រឹត្តិទៅនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង១៥:៣០ រសៀល។

**ឯកឧត្តម ហង្ស ឆាំឆាន** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នឹងអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១០:៣០នាទី នៅវត្តឧត្តរាវតី ឬស្សីកែវ (ទល់មុខ CTN)។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាចូលរួមរំលែកទុក្ខ និងចាប់មគ្គផលតាមលទ្ធភាពជាក់ស្តែង។

ថ្ងៃ អង្គារ ៦ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## ឯកឧត្តម រោង ឈង ទីប្រឹក្សាក្រសួង និងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្ដីសោកស្ដាយរញ្ជួយក្រៃលែង ដោយបានទទួលដំណឹងថា ឧបាសក ទៀង ជិន ដែលត្រូវជាឪពុកក្មេក ឯកឧត្តម រោង ឈង ទីប្រឹក្សាក្រសួង បានទទួលមរណភាពនៅថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ០០:៥០នាទីព្រឹក ក្នុងជន្មាយុ ៨៦ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្ដីរំជួលចិត្តនិងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្ដែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្ដាយជាអនេកប្បការជាមួយឯកឧត្តម និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ ឧបាសក ទៀង ជិន ដែលជាស្វាមី ឪពុក និងជីតាជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ ឧបាសក ទៀង ជិន បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ អង្គារ ៦ រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១
រដ្ឋមន្ត្រី

ព្រុំ សុខា